# តំណាងពិសេសរបស់លោកអគ្គលេខាធិការ
# ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លោក យ៉ាសហ៊ ហ្កាយ

## សេចក្តីថ្លែងការណ៍ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៦

ខ្ញុំបានបំពេញបេសកកម្មចំនួនពីរលើកមកកាន់ប្រទេសកម្ពុជា ចាប់តាំងពីខ្ញុំបានទទួលការតែងតាំងក្នុងខែវិច្ឆិកា ឆ្នាំ២០០៥។ ក្នុងការបំពេញអាណត្តិរបស់ខ្ញុំ ខ្ញុំបានទទួលការចង្អុលបង្ហាញដោយអនុសាសន៍ជាច្រើនរបស់អតីតតំណាងពិសេសដ៏ល្បីឈ្មោះចំនួនបីរូប ដោយគណៈកម្មការសិទ្ធិមនុស្ស ដោយមហាសន្និបាត និងដោយបទបញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងឆ្នាំ១៩៩១ ស្តីពីដំណោះស្រាយនយោបាយរួមនៃជំលោះកម្ពុជា។ ខ្ញុំយល់ឃើញថា ការទទួលខុសត្រូវសំខាន់បំផុតរបស់ខ្ញុំ គឺការរួមចំណែកប្តេជ្ញាចិត្តក្នុងន័យស្ថាបនាជាមួយរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា។

បន្ទាប់ពីខ្ញុំបានធ្វើទស្សនកិច្ចលើកទីមួយនៅឆ្នាំកន្លងទៅនេះ ខ្ញុំបានរៀបចំរបាយការណ៍លំអិតមួយ ដោយធ្វើការវិភាគអំពីស្ថានការណ៍សិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យ ហើយបានផ្តល់អនុសាសន៍មួយចំនួន។ ខ្ញុំសូមនិយាយដោយចំហរប្រាប់ក្រុមប្រឹក្សាសិទ្ធិមនុស្ស  ក្នុងស្មារតីដែលក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើង ដើម្បីធានាការអនុវត្តន៍សិទ្ធិមនុស្សយ៉ាងពេញលេញនៅទូទាំងពិភពលោក ។

ខ្ញុំមានការព្រួយបារម្ភដោយសារថា អនុសាសន៍របស់ខ្ញុំ ឬអនុសាសន៍របស់អតីតតំណាងពិសេសនានាត្រូវបានអនុវត្តតិចតួចបំផុត ហើយថាការរំលោភសិទ្ធិមនុស្សនៅតែបន្តកើតមានក្នុងកំរិតជាប្រព័ន្ធ។ ខ្ញុំយល់ថា បញ្ហានេះមិនមែនកើតឡើងដោយសារតែការធ្វេសប្រហែស ឬការខ្វះការយល់ដឹងអំពីសិទ្ធិ ឬការខ្វះវិធានស្តីពីនីតិវិធី និងស្ថាប័ន ដើម្បីធានាការពារសិទ្ធិទាំងនេះ ឬដោយហេតុថា ប្រទេសកម្ពុជាបានទទួលរងការឈឺចាប់ធ្ងន់ធ្ងរបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬពីព្រោះតែភាពក្រីក្រ ដែលបញ្ហានេះជារឿយៗត្រូវបានលើកមកសំអាងឡើយ។ គេមិនចាំបាច់ទាល់តែមានជំនាញខាងសិទ្ធិមនុស្ស ដើម្បីដឹងថាគោលនយោបាយជាច្រើនរបស់រដ្ឋាភិបាលបានធ្វើឱ្យខូចដល់គោលការណ៍គ្រឹះនៃលិទ្ធិប្រជាធិបតេយ្យ និងនីតិវិធីត្រឹមត្រូវ ការដកហូតពីប្រជាជននូវធនធានសេដ្ឋកិច្ច និងមធ្យោបាយក្នុងការចិញ្ចឹមជីវិត និងបានបដិសេធមិនទទួលស្គាល់សេចក្តីថ្លៃថ្នូររបស់ប្រជាជន។ ខ្ញុំជឿថា គោលនយោបាយទាំងនេះគឺជាស្នូលនៃប្រព័ន្ធសេដ្ឋកិច្ច និងនយោបាយ ដែលតាមរយៈនេះ រដ្ឋាភិបាលជាអ្នកសំរេច និងបានបំភ្លៃលទ្ធិប្រជាធិបតេយ្យ ដើម្បីធ្វើឱ្យគណបក្សប្រឆាំងស្របច្បាប់ចុះខ្សោយ ហើយបានប្រើឈ្មោះរដ្ឋ ដើម្បីប្រមូលយកទ្រព្យសម្បត្តិមកធ្វើជារបស់ឯកជន។ ច្បាប់ ឬការអនុវត្តន៍រិតត្បិតសិទ្ធិប្រជាពលរដ្ឋក្នុងការបង្កើតសមាគម សិទ្ធិជួបប្រជុំ ឬសិទ្ធិសំដែងមតិរបស់ខ្លួនដោយសេរី។  ស្ថាប័នធំៗទាំងអស់

ដែលបានបង្កើតដោយរដ្ឋធម្មនុញ្ញត្រូវបានធ្វើឱ្យចុះខ្សោយ ធ្វើឱ្យគោលការណ៍បែងចែកអំណាចគ្មានប្រសិទ្ធិភាព ដែលគោលការណ៍នេះមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ប្រព័ន្ធច្បាប់មិនបានផ្តល់ការដោះស្រាយ ឬការការពារសហគមន៍នានា ឬឯកត្តបុគ្គលឡើយ។ រដ្ឋាភិបាលបានប្រើប្រាស់ព្រះរាជអាជ្ញា និងចៅក្រមធ្វើជាលេស ដើម្បីលើកស្ទួយឯករាជ្យភាព ដើម្បីបំភិតបំភ័យ ឬផ្តន្ទាទោសអ្នកដែលខ្លួនមិនចូលចិត្ត ឬដែលខ្លួនស្អប់។ រដ្ឋាភិបាលបានអនុវត្តច្បាប់ដោយរើសអើង ហើយអ្នកគាំទ្រខ្លួនបានទទួលអភ័យឯកសិទ្ធិរួចផុតពីចំណាត់ការផ្នែកព្រហ្មទណ្ឌចំពោះការរំលោភច្បាប់ជាក់ស្តែង។ សរុបសេចក្តីមក ខ្ញុំយល់ថាការច្រានចោលដោយចេតនានូវគោលគំនិតដែលថា រដ្ឋត្រូវបានគ្រប់គ្រងដោយវិធានច្បាប់( នីតិរដ្ឋ) គឺជាចំណុចស្នូលរបស់គណបក្សកំពុងកាន់អំណាច។

របាយការណ៍របស់ខ្ញុំ និងរបាយការណ៍របស់អតីតតំណាងពិសេសផ្តល់ភស្តុតាងគ្រប់គ្រាន់សំរាប់ធ្វើសេចក្តីសន្និដ្ឋាននេះ។ ឥឡូវនេះ ខ្ញុំសូមលើកយកករណីថ្មីៗមួយចំនួនមកធ្វើការអះអាងបញ្ជាក់។

*ការត្រួតត្រាលើបរិយាកាសនយោបាយ*

គណបក្សប្រជាជនកម្ពុជា បានបង្កើតការត្រួតត្រាលើយន្តការទាំងអស់នៃប្រទេសកម្ពុជា តាមរយៈមធ្យោបាយជាច្រើន រួមទាំងការត្រួតត្រាយ៉ាងណែនទៅលើគណៈកម្មការរៀបចំការបោះឆ្នោត និងការបំភិតបំភ័យអ្នករិះគន់ និងគណបក្សប្រឆាំងរបស់ខ្លួន។ ក្រោយពីការបង្កើតរដ្ឋាភិបាលថ្មីក្នុងខែកក្កដា ឆ្នាំ២០០៤ គណបក្សនេះបានប្រើប្រាស់សំលេងភាគច្រើនលើសលុបក្នុងរដ្ឋសភា ដើម្បីបដិសេធសមាជិកភាពគណបក្សប្រឆាំងធំមួយ គឺគណបក្សសមរង្ស៊ី មិនឱ្យចូលរួមក្នុងគណៈកម្មការនានានៃសភា ហើយបន្ទាប់មកបានដកអភ័យឯកសិទ្ធិរដ្ឋសភាពីប្រធានគណបក្សនេះ និងពីសហការីរបស់គាត់ពីររូបទៀតនៅដើមឆ្នាំ២០០៥។ នៅចុងឆ្នាំនោះដែរ អ្នករិះគន់គណបក្សប្រជាជនមួយចំនួនត្រូវបានចាប់ខ្លួន ឬបានបង្ខំឱ្យនិរទេសខ្លួន និងបានចោទប្រកាន់ពីបទល្មើសផ្សេងៗ រួមទាំងបទបរិហារកេរ្តិ៍ផងដែរ។ មានការចរចាគ្នាមួយជាមួយនាយករដ្ឋមន្ត្រីនៅដើមឆ្នាំនេះ ដែលអាចឱ្យអ្នកទាំងនោះវិលត្រឡប់ចូលស្រុកវិញ ហើយបានព្យួរការចោទប្រកាន់ទៅលើពួកគេ ទោះជាការចោទប្រកាន់នោះនៅតែមានក៏ដោយ។ លោក សម រង្ស៊ី ត្រូវបានតុលាការបើកសវនាការកំបាំងមុខកាត់ទោសពីបទបរិហារកេរ្តិ៍ ត្រូវបានលើកលែងទោស ជាមួយនឹងតំណាងរាស្ត្រមួយរូបនៃគណបក្សលោកផងដែរ ការកាត់ទោសបន្ទាប់ពីសវនាការនេះមិនបានបំពេញតាមនិយាមស្តីពីនីតិវិធីត្រឹមត្រូវដែលបានទទួលស្គាល់នោះឡើយ។ ការព្យួរ ឬការលើកលែងចោទប្រកាន់ ឬការលើកលែងទោស គឺជាការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា និងព្រះមហាក្សត្រ រៀងៗខ្លួន។ ប៉ុន្តែនៅតែមានការចរចា និងការលើកលែងទោសដ៏មានប្រសិទ្ធិភាពដោយនាយករដ្ឋមន្ត្រី។

ក្នុងខែសីហា ឆ្នាំ២០០៦ មានការធ្វើវិសោធនកម្មច្បាប់ ដែលធ្វើឱ្យតំណាងរាស្ត្រប្រឈមនឹងគ្រោះថ្នាក់។ ផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ និងបទដ្ឋានអន្តរជាតិ ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្របានកំណត់អំពីគុណសម្បត្តិផ្សេងៗចំពោះអភ័យឯកសិទ្ធិរបស់ពួកគេពាក់ព័ន្ធនឹងសេរីភាពក្នុងការសំដែងមតិ។ ច្បាប់នេះបានបើកផ្លូវឱ្យសមាជិកសភាដែលមានមតិ " រំលោភ " លើសេចក្តីថ្លៃថ្នូររបស់បុគ្គល ទំនៀមទំលាប់សង្គម របៀបរបបសាធារណៈ និងសន្តិសុខជាតិ ទទួលទោសតាមច្បាប់ដូចគ្នានឹងការរិតត្បិតសេរីភាពក្នុងការសំដែងមតិនៃប្រជាពលរដ្ឋកម្ពុជាសាមញ្ញដែរ ។ ច្បាប់ដដែលនេះអនុញ្ញាតឱ្យចាប់ខ្លួនតំណាងរាស្ត្រដោយមិនចាំបាច់ដកអភ័យឯកសិទ្ធិជាមុនឡើយ។

ការត្រួតត្រាខាងនយោបាយត្រូវបានពង្រឹងដោយការចោទប្រកាន់ ឬ ការគំរាមចោទប្រកាន់ក្រោមច្បាប់ដាក់ការបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌ ។ បញ្ញត្តិច្បាប់នេះត្រូវគេប្រើជាទូទៅនៅក្នុងឆ្នាំ២០០៥ ( ប្រឆាំងនឹងអ្នកនយោបាយ អ្នកកាសែត បុគ្គលិកសហជីពកម្មករ និងសកម្មជនសិទ្ធិមនុស្ស) បាននាំឱ្យមានការរិះគន់ និងការដាក់គំនាបជាច្រើនពីសំណាក់សហគមន៍ជាតិ និងសហគមន៍អន្តរជាតិសុំឱ្យលុបបញ្ញត្តិនេះចោល ។ ច្បាប់នេះត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៦ ដើម្បីដកចេញនូវទោសគុក ប៉ុន្តែបទល្មើសនេះ ត្រូវបានគេរក្សាទុកដដែល ។ ចាប់តាំងពីពេលនោះមក រដ្ឋាភិបាលបានប្រើបញ្ញត្តិច្បាប់មួយទៀត ស្តីពី "ការផ្សាយព័ត៌មានមិនពិត " ដូច្នេះ ជនណាដែលធ្វើឱ្យរដ្ឋាភិបាលមិនសប្បាយចិត្តនៅតែអាចទទួលទោសគុកជាដដែល ហើយត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នរងចាំសវនាការ ។ រដ្ឋាភិបាលក៏បានប្រើបញ្ញត្តិស្តីពីការញុះញង់ ដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគាររយៈពេលរហូតដល់ប្រាំឆ្នាំ ។

ចាប់តាំងពីឆ្នាំ២០០៣ រដ្ឋាភិបាលបានហាមប្រាមការធ្វើបាតុកម្ម ការដង្ហែ និងការដើរជាក្បួន ដើម្បីមូលហេតុ " រក្សារបៀបរៀបរយ ឬសន្តិសុខសាធារណៈ" ។ ការជួបប្រជុំដោយសន្តិវិធី ត្រូវបានអាជ្ញាធររដ្ឋបំបែក ដោយការប្រើប្រាស់អាវុធ និងដោយរូបភាពផ្សេងៗនៃអំពើហិង្សា ។ សេចក្តីព្រាងច្បាប់ស្តីពីការប្រជុំជាសាធារណៈមិនទាន់បំពេញតាមបទដ្ឋានអន្តរជាតិដែលប្រទេសកម្ពុជាបានចុះហត្ថលេខាទទួលស្គាល់នៅឡើយទេ ។

*ការធ្វើឱ្យខូចដល់ច្បាប់ និងប្រព័ន្ធតុលាការ*

រដ្ឋាភិបាលបានធ្វើឱ្យខូចដល់គោលគំនិតនៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលបង្កើតឱ្យមានប្រព័ន្ធច្បាប់មួយមានប្រសិទ្ធិភាព ដើម្បីការពារសិទ្ធិប្រជាពលរដ្ឋ និងការបង្កើតនីតិរដ្ឋ ។ ច្បាប់មួយចំនួនដែលសំខាន់ចាំបាច់សំរាប់បង្កើតឱ្យមានប្រព័ន្ធច្បាប់ នៅមិនទាន់បានអនុម័តនៅឡើយទេ ទោះបីជាច្បាប់ទាំងនេះត្រូវបានដាក់ក្នុងរបៀបវារៈជាច្រើនឆ្នាំកន្លងមកហើយៗមានការផ្តល់ជំនួយអន្តរជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ក៏ដោយ ។ រដ្ឋាភិបាលក៏បានធ្វើឱ្យខូចដល់ឯករាជ្យភាពនៃអំណាចតុលាការ និងអំណាចខាងអយ្យការ ដែលអំណាចទាំងនេះត្រូវស្ថិតក្រោមការការពាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលដឹកនាំដោយព្រះមហាក្សត្រ ។ រដ្ឋាភិបាលបានដកលេខាធិការដ្ឋាននៃក្រុមប្រឹក្សានេះទៅដាក់នៅក្រសួងយុត្តិធមិ ដែលមានភារកិច្ចសំរេចលើការចោទប្រកាន់ផ្សេងៗ ។ អ្នកគាំទ្ររដ្ឋាភិបាលទាំងអស់ស្ទើរតែមិនត្រូវបានគេចោទប្រកាន់ឡើយ ។ អតីតតំណាងពិសេសបានគូសបញ្ជាក់ជាច្រើនលើកច្រើនសារអំពីការផ្តល់អភ័យឯកសិទ្ធិច្រើនលើសលុបឱ្យទៅអ្នកទាំងនោះ ចំពោះការប្រព្រឹត្តរំលោភច្បាប់ធ្ងន់ធ្ងរបំផុត ។ ទន្ទឹមនឹងនេះ មានការចោទប្រកាន់មិនត្រឹមត្រូវទៅលើអ្នកប្រឆាំងនឹងរដ្ឋាភិបាល ឬ អ្នកដែលតស៊ូដើម្បីលិទ្ធិប្រជាធិបតេយ្យ និងសិទ្ធិ ។

មានភស្តុតាងប្រយោលជាច្រើន ដែលបង្ហាញពីការដែលអំណាចនីតិប្រតិបត្តិប្រើប្រាស់ប្រព័ន្ធតុលាការមិនបានត្រឹមត្រូវ ។ នៅក្នុងករណីរឿងជាក់ស្តែងមួយ មានមនុស្សពីរនាក់ ដែលគេស្គាល់ទូទៅថាជាជនស្លូតត្រង់ ត្រូវបានចាប់ខ្លួនពីបទឃាតកម្មលើប្រធានសហជីពកម្មករដ៏ល្បីឈ្មោះមួយរូប ។ តុលាការបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល២០ ឆ្នាំ ។ មានភស្តុតាងថ្មីទៀត ដែលបញ្ជាក់ថា ពួកគេគ្មានទោស ហើយអ្នកដែលទទួលខុសត្រូវពិតប្រាកដកំពុងស្ថិតក្នុងការគេចខ្លួន ។ ចៅក្រមតុលាការក្រុងភ្នំពេញមួយរូបដែលបានចាត់តាំងឱ្យស៊ើបអង្កេតករណីនេះ បានលើកលែងការចោទប្រកាន់ ដោយសារគ្មានភស្តុតាងគ្រប់គ្រាន់ ។ ចៅក្រមរូបនោះ ត្រូវបាន

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដកហូតពីមុខតំណែង ហើយបន្ទាប់មកត្រូវបានចាត់តាំងឱ្យទៅបំរើការនៅតុលាការក្នុងខេត្តមួយដាច់ស្រោល ហើយក្នុងខណៈពេលនោះដែរ តុលាការបានធ្វើការចោទប្រកាន់ជនជាប់ចោទនោះជាថ្មីទៀត ។ នៅក្នុងករណីរឿងនយោបាយជាច្រើន ចៅក្រមសំរេចផ្តន្ទាទោសដោយផ្អែកលើភស្តុតាងមិនរឹងមាំ ឬការបកស្រាយច្បាប់មិនបានត្រឹមត្រូវ ។ តុលាការក្លាយជាកន្លែងមួយដែលពួកគេងាយទាញយកប្រយោជន៍ ជារឿយៗគេតែងដាក់ពាក្យបណ្តឹងទៅតុលាការផ្ទាល់តែម្តង ដោយរំលងស្ថាប័ន និងនីតិវិធីនានាដែលច្បាប់បានកំណត់ ដើម្បីឱ្យខ្លួនឈ្នះក្តីនៅតុលាការ ។ ឧទាហរណ៍ជាក់ស្តែងមួយ គឺការដាក់ពាក្យបណ្តឹងទៅតុលាការផ្ទាល់តែម្តង ដោយរំលេងគណៈកម្មការសុរិយោដី ដែលមានចែងក្នុងច្បាប់ភូមិបាល ឆ្នាំ២០០១ ដែលបណ្តាលឱ្យមានការដកហូតយកដីធ្លីពីប្រជាជនក្រីក្រ ។ ក្រៅពីនេះ ការអនុវត្តន៏និងការប្រើប្រាស់ទោសបញ្ញត្តិក៏មានការរើសអើងដែរ នៅក្នុងច្បាប់ភូមិបាល ។ ព្រោះថាបញ្ញត្តិច្បាប់នេះមិនបានការពារសិទ្ធិលើដីធ្លីរបស់ប្រជាជនដែលគ្មានអំណាចទេ ក្នុងនោះរួមមានជនជាដើមភាគតិចផងដែរ ជារឿយៗពួកគេតែងស្នើសុំឱ្យជួយទាមទារដីរបស់ខ្លួនពីជនដែលមានអំណាចខាងនយោបាយ និងពីជនដែលមានទ្រព្យសម្បត្តិច្រើន ឬ ពីជនដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយមនុស្សដែលមានឥទ្ធិពលខ្លាំង ។

*អំពើពុករលួយ*

អំពើពុករលួយត្រូវបានគេស្គាល់ជាទូទៅថាមានការរីករាលដាលខ្លាំង ដែលបញ្ហានេះ រដ្ឋាភិបាលបានទទួលរងការគាបសង្កត់ឱ្យដោះស្រាយ ហើយរដ្ឋាភិបាលខ្លួនឯងផ្ទាល់ក៏បានសំដែងការព្រួយបារម្ភចំពោះបញ្ហានេះផងដែរ ។ នៅក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ មានភស្តុតាងអាចជឿបាននៃអំពើពុករលួយក្នុងទ្រង់ទ្រាយធំមួយ នៅក្នុងក្រសួងស្ថាប័នមួយចំនួនរបស់រដ្ឋាភិបាលដែលបានស្តែងឱ្យឃើញយ៉ាងច្បាស់ ។ ព្រោះតែហេតុហ្នឹងហើយបានជារដ្ឋាភិបាលបន្តជំនះមិនព្រមអនុម័តច្បាប់ដ៏មានប្រសិទ្ធិភាពនេះ ដែលបានពិភាក្សាចាប់ពីឆ្នាំ១៩៩៥ រហូតមក បើទោះជាមានការគាបសង្កត់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិក៏ដោយ ហើយផ្ទុយទៅវិញ រដ្ឋាភិបាលបែរជាបង្កើតស្ថាប័នរដ្ឋបាលមួយ ដើម្បីធ្វើការស៊ើបអង្កេតអំពើពុករលួយ ដែលស្ថាប័ននេះដឹកនាំដោយមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជន ដែលទទួលបានការជឿទុកចិត្តតិចតួច ?

*យុត្តិធម៌សង្គម និងធនធានធម្មជាតិ*

រយៈកាលជាច្រើនឆ្នាំមកនេះ មានប្រជាពលរដ្ឋរាប់ពាន់គ្រួសារត្រូវបានគេជម្លៀសដោយបង្ខំ និងដោយខុសច្បាប់ចេញពីផ្ទះសម្បែង និងដីធ្លីរបស់ខ្លួន នៅរាជធានីភ្នំពេញ និងនៅតំបន់ផ្សេងៗទៀត ជាអាទិ៍គឺការដណ្តើមយកដីធ្លី ដែលមានការគិតគូតិចតួចបំផុតអំពីច្បាប់ ហើយប្រជាពលរដ្ឋដែលបាត់បង់ដីធ្លីមិនបានទទួលសំណងលើការខូចខាតឡើយ ។ ប្រជាពលរដ្ឋជាច្រើនបានរងផលប៉ះពាល់ការចិញ្ចឹមជីវិត ទាំងការងារធ្វើស្រែចំការ ទាំងការងារនៅទីក្រុង ។ ប្រជាពលរដ្ឋបាត់បង់ការជឿជាក់លើប្រព័ន្ធច្បាប់ ។ ខ្ញុំនៅចាំច្បាស់នៅពេលដែលខ្ញុំនិយាយជាមួយប្រជាពលរដ្ឋដែលត្រូវគេដណ្តើមយកដីធ្លីរបស់ខ្លួន គាត់បានសំដែងក្តីអស់សង្ឃឹមនៅពេលដឹងថាអ្នកដណ្តើមយកដីគាត់ បានដាក់ពាក្យបណ្តឹងទៅតុលាការ ពីព្រោះគេអាចទស្សទាយបានយ៉ាងងាយបំផុតពីសេចក្តីសំរេចរបស់តុលាការ ។ ភាពគ្មានអំណាចរបស់ខ្លួនមានន័យជ្រៅ ហើយវាអាចក្លាយជាឧបសគ្គច្រើនថែមទៀត ។

សហគមន៍ជនជាតិដើមភាគតិចជាច្រើនជួបប្រទះបញ្ហាពិសេសនៃការដែលគេដណ្ដើមយកដីធ្លីរបស់ខ្លួន ។ ដីធ្លីគឺជាកត្តាសំខាន់បំផុតសំរាប់ការបង្កើតសហគមន៍ផ្សេងៗ ការបាត់បង់ទឹកដីធ្វើឱ្យអន្តរាយដល់ឯកភាពនៃសហគមន៍ និងនាំឱ្យសង្គមបែកបាក់ ។ រដ្ឋាភិបាលមិនទាន់បានអនុម័តច្បាប់ ដើម្បីការពារដីធ្លីរបស់ជនជាតិដើមភាគតិចនៅឡើយទេ បើទោះជាមានការសន្យាហើយក៏ដោយ ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលមិនបានយកចិត្តទុកដាក់ចំពោះអនុសាសន៍ដែលស្នើឱ្យផ្អាកជាបណ្ដោះអាសន្នការលក់ ឬ ការផ្ទេរកម្មសិទ្ធិលើដីធ្លី រហូតដល់ច្បាប់ពាក់ព័ន្ធត្រូវបានអនុម័តជាមុនឡើយ ។

រដ្ឋាភិបាលបានផ្ដល់ដីសម្បទានយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅឱ្យក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេសនានា និងយោធា ដោយមិនបានបញ្ចេញឱ្យដឹងជាសាធារណៈ ឬ ដោយគ្មានតម្លាភាព ឬ ដោយគ្មានការពិគ្រោះយោបល់ជាមួយសហគមន៍ ដែលត្រូវគេដណ្ដើមយកដីធ្លីនោះទេ ។ ការនេះជំរុញឱ្យខ្ញុំចោទជាសំណួរថាតើដីណាខ្លះ ហើយមានចំនួនប៉ុន្មានដែលនៅសល់សំរាប់ផ្ដល់ឱ្យប្រជាជនកម្ពុជាសាមញ្ញទាំងនោះ ។ ការបញ្ចេញឱ្យដឹង និងការទទួលបានព័ត៌មានរិតតែសំខាន់ថែមទៀត ពាក់ព័ន្ធនឹងរបកគំហើញនៃធនធានរ៉ែ ប្រេងសំខាន់នៅក្នុងឈូងសមុទ្រថៃឡង់ដ៏ ។ បើតាមសេចក្ដីរាយការណ៍ មានក្រុមហ៊ុនប្រេងឥន្ទនៈបរទេសមួយចំនួនបានចុះកិច្ចសន្យាធ្វើអាជីវកម្មរបស់ខ្លួន ប៉ុន្តែខ្ញុំដឹងថា កិច្ចសន្យាទាំងនេះមិនបានបញ្ចេញឱ្យដឹងជាសាធារណៈដោយមន្ទីរពាក់ព័ន្ធរបស់រដ្ឋាភិបាលឡើយ ។

*ការទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ*

សហគមន៍អន្តរជាតិ តាមរយៈអង្គការសហប្រជាជាតិ និង មធ្យោបាយពហុភាគី និងទ្វេរភាគីដទៃទៀត ប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវពិសេសមួយ ដើម្បីជួយគាំទ្រប្រទេសកម្ពុជា និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ និងការទទួលខុសត្រូវ ។ ប៉ុន្តែការងាររបស់ខ្លួនត្រូវផ្អែកលើការវិភាគយ៉ាងហ្មត់ចត់អំពីហេតុការណ៍ដែលកើតមាន នៃស្ថានភាពលំបាកលំបិននៃសិទ្ធិមនុស្ស និងយុត្តិធម៌សង្គមក្នុងប្រទេសកម្ពុជា ។

ប្រទេសជិតខាងកម្ពុជា និងរដ្ឋាភិបាលនានាដែលមានឥទ្ធិពលក្នុងតំបន់អាស៊ីគួរតែចូលរួមយ៉ាងសកម្មច្រើនថែមទៀត ក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួនចំពោះប្រទេសកម្ពុជា និងប្រជាជនកម្ពុជា ក្នុងនាមជាភាគីនៃធម្មនុញ្ញសហប្រជាជាតិ និង សន្ធិ-សញ្ញាសិទ្ធិមនុស្សអន្តរជាតិ ក៏ដូចជាភាគីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ។ ក្នុងនោះមានប្រទេសខ្លះក៏ជាសមាជិកនៃក្រុមប្រឹក្សាសិទ្ធិមនុស្សនេះដែរ ។

ការផ្ដល់ជំនួយ ត្រូវភ្ជាប់ជាមួយនូវការទទួលខុសត្រូវ ដើម្បីធានាថាជំនួយនោះជួយដល់ប្រជាជន ។ ប្រទេសអ្នកផ្ដល់ជំនួយ និងសហគមន៍អន្តរជាតិក្នុងប្រទេសកម្ពុជាត្រូវផ្ដល់អាទិភាពខ្ពស់បំផុតចំពោះសិទ្ធិមនុស្ស និងធ្វើការតស៊ូមតិយ៉ាងសកម្មចំពោះការអនុវត្តន៍របស់ខ្លួន ។ ពួកគេត្រូវគាំទ្រយ៉ាងខ្លាំងក្លាដល់ប្រជាពលរដ្ឋក្រីក្រ និងសហគមន៍ដែលគ្មានអំណាច និងអង្គការក្រៅរដ្ឋាភិបាលកម្ពុជា ដែលការពារសិទ្ធិមនុស្ស និងធ្វើការដើម្បីសិទ្ធិមនុស្ស ។ ការពឹងផ្អែកលើជំនួយបច្ចេកទេស និងការកសាងសមត្ថភាព ឬការគួសបញ្ជាក់ពីការប្រកាន់ខ្ជាប់នូវសន្ធិសញ្ញា និងពិធីសារស្ដីពីសិទ្ធិមនុស្ស (ដែលមានសារៈសំខាន់ដូចនេះ) តែប៉ុណ្ណឹងគឺមិនគ្រប់គ្រាន់ទេ ។ ដូចគ្នានេះដែរ ច្បាប់ថ្មី ឬស្ថាប័នដែលទើបបង្កើតថ្មីក៏គ្មានន័យដែរ សំរាប់រដ្ឋាភិបាលមួយមិនសូវយកចិត្តទុកដាក់គោរពច្បាប់ ឬតាម

រយៈការរំលោភ ការបង្វែរច្បាប់នោះឱ្យបំរើផលប្រយោជន៍បក្សពួកខ្លួន ហើយរដ្ឋាភិបាលបានបង្កើតស្ថាប័នថ្មីៗ ជាជាងការធ្វើយ៉ាងណាឱ្យស្ថាប័នទាំងឡាយ ដែលមានស្រាប់ដំណើរការល្អនោះ ។

ខ្ញុំបានទទួលដំណឹងថា នៅព្រឹកនេះ លោកនាយករដ្ឋមន្ត្រីបានបើកសន្និសិទមួយស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិក្នុងប្រទេសកម្ពុជា ។ ខ្ញុំសង្ឃឹមថាព្រឹត្តិការណ៍នេះនឹងបញ្ជាក់ពីការចាប់ផ្តើមនៃការពិភាក្សាដ៏ពិតប្រាកដមួយ ដើម្បីសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា និងការព្រមព្រៀងថា ច្បាប់ជាមូលដ្ឋាន និងស្ថាប័នឯករាជ្យនានា រួមទាំងប្រព័ន្ធតុលាការមួយដែលមានវិជ្ជាជីវៈ និងមិនលំអៀង ត្រូវតែមានមុនគេបង្អស់ ។ បើសិនជាគ្មានកត្តាទាំងនេះទេ ស្ថាប័ននេះមិនអាចដំណើរការប្រកបដោយប្រសិទ្ធិភាពឡើយ ។

រដ្ឋាភិបាលប្រាកដជាយល់ថា អ្វីដែលខ្ញុំនិយាយនេះគឺមិនត្រឹមត្រូវទេ ប៉ុន្តែខ្ញុំសូមអញ្ជើញរដ្ឋាភិបាលមេត្តារាយការណ៍ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អំពីវិធានការជាក់ស្តែងមួយចំនួនដែលរដ្ឋាភិបាលបានចាត់ឡើង និងអំពីចេតនាចង់ដោះស្រាយបញ្ហាទាំងឡាយដែលខ្ញុំនិងអ្នកដទៃទៀតបានលើកឡើង និងដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ផ្សេងៗដែលខ្ញុំ និងអតីតតំណាងពិសេសបានស្នើឡើង ក៏ដូចជាអនុសាសន៍ផ្សេងទៀតរបស់សហគមន៍អន្តរជាតិដែលបានធ្វើឡើង តាមរយៈសេចក្តីសំរេចចិត្តនៃមហាសន្និបាតអង្គការសហប្រជាជាតិ និងគណៈកម្មការសិទ្ធិមនុស្ស និងអនុសាសន៍របស់ស្ថាប័នសន្ធិសញ្ញានានា ។

ខ្ញុំបានធ្វើទស្សនកិច្ចជាលើដំបូងនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩២ ហើយបានឃើញស្ថានការណ៍អាក្រក់បំផុតនៃប្រទេសមួយក្រោយពីបានងើបពីសង្គ្រាម និងជំលោះស៊ីវិលជាច្រើនឆ្នាំ ។ ខ្ញុំទទួលស្គាល់ការរីកចំរើនក្នុងការកសាងប្រទេសកម្ពុជាឡើងវិញ ។ ប៉ុន្តែទោះជាដូច្នេះក៏ដោយ រហូតមកទល់ពេលនេះមានរយៈពេលដប់ប្រាំឆ្នាំហើយ បន្ទាប់ពីការអនុម័តកិច្ចព្រមព្រៀងទីក្រុងប៉ារីស បទបញ្ញត្តិស្តីពីសិទ្ធិមនុស្សមិនទាន់បានបំពេញបានពេញលេញនៅឡើយទេ ។ ខ្ញុំយល់ថាកង្វល់ស្តីពីរបាយការណ៍សិទ្ធិមនុស្សរបស់រដ្ឋាភិបាលកម្ពុជា ត្រូវតែបានសំដែងចេញជាពាក្យពេចន៍ច្បាស់លាស់ដោយគ្មានការលាក់លៀម ប្រសិនបើរដ្ឋាភិបាលពិតរក្សាពាក្យសន្យារបស់ខ្លួន ។

ខ្ញុំសង្ឃឹមថានឹងបន្តពិភាក្សាអំពីបញ្ហាទាំងឡាយ ដែលខ្ញុំបានលើកឡើងនៅក្នុងបេសកកម្មលើកទីបីរបស់ខ្ញុំមកកាន់ប្រទេសកម្ពុជាក្នុងខែវិច្ឆិកាខាងមុខនេះ ។